ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ០៦៤ សណ៍ ធទឧ

# សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពអាកាសធាតុ

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ៖ ក្នុងពេលបច្ចុប្បន្ននេះ បាតុភូត El Nino ( ក្តៅ ) បានចាប់ផ្តើមថយឥទ្ធិពលបន្តិចម្តងៗ ។ បាតុភូត Dipole Model Index នឹងចូលមកជំនួស ហើយរហូតដល់ចុងខែកក្កដា ឆ្នាំ 2016 ទើបបាតុភូត La Nina ( ត្រជាក់ ) ចាប់មានឥទ្ធិពលវិញ ។ បាតុភូតធម្មជាតិនេះ នឹងធ្វើឱ្យអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា មានស្ថានភាពដូចខាងក្រោម ៖

- **នៅរដូវប្រាំង** ៖ ក្នុងខែមីនា និងខែមេសា ធាតុអាកាសនឹងក្តៅហួតហែងខ្លាំង បរិមាណទឹកភ្លៀងកក់ខែមានចំនួនតិចតួច ហើយបាតុភូតផ្គរ រន្ទះ ខ្យល់កន្ត្រាក់ នឹងកើតឡើងច្រើន ។
- **នៅដើមរដូវវស្សា** ៖ ចាប់ពីខែឧសភា ដល់ខែកក្កដា មានភ្លៀងតិច មានបាតុភូតផ្គរ រន្ទះ និងខ្យល់កន្ត្រាក់កើតឡើងច្រើន ។ កូនរដូវប្រាំងនឹងកើតមានចាប់ពីពាក់កណ្តាលខែកក្កដា ដល់ចុងខែកក្កដា ។
- របាយទឹកភ្លៀងនឹងចាប់ផ្តើមធ្លាក់ច្រើន ហើយរាយប៉ាយបានល្អ ចាប់ពីពាក់កណ្តាលរដូវវស្សា រហូតដល់ចុងរដូវវស្សា ( ចាប់ពីខែសីហា ដល់ចុងខែវិច្ឆិកា ) ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន ពិសេសបងប្អូនប្រជាកសិករ ជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh